# អានាបានស្សតិសូត្រ

ឯវម្មេ សុតំ *សូត្រនេះឈ្មោះអានាបានស្សតិសូត្រ គឺខ្ញុំឈ្មោះអានន្ទបានស្តាប់មកហើយយ៉ាងនេះថា*

ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ សម្ពហុលេហិ អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ *សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទមិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ព្រមដោយសាវកទាំងឡាយ ជាថេរៈច្រើនរូប ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាងគេ។*

អាយស្មតា ច សារិបុត្តេន អាយស្មតា ច មហាមោគ្គល្លានេន អាយស្មតា ច មហាកស្សបេន អាយស្មតា ច មហាកច្ចាយនេន អាយស្មតា ច មហាកោដ្ឋិកេន អាយស្មតា ច មហាកប្បិនេន អាយស្មតា ច មហាចុន្ទេន អាយស្មតា ច អនុរុទ្ធេន អាយស្មតា ច រេវតេន អាយស្មតា ច អានន្ទេន អញ្ញេហិ ច អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ *គឺព្រះសារីបុត្រមានអាយុ ១ ព្រះមហាមោគ្គល្លានមានអាយុ ១ ព្រះមហាកស្សបៈមានអាយុ ១ ព្រះមហាកច្ចាយនៈមានអាយុ ១ ព្រះមហាកោដ្ឋិតៈមានអាយុ ១ ព្រះមហា-កប្បិនមានអាយុ ១ ព្រះមហាចុន្ទមានអាយុ ១ ព្រះអនុរុទ្ធមានអាយុ ១ ព្រះរេវតៈមានអាយុ ១ ព្រះអានន្ទមានអាយុ ១ ព្រមដោយសាវកទាំងឡាយជាថេរៈដទៃ ៗ ទៀត ដែលមានឈ្មោះល្បីល្បាញ ។*

តេន ខោ បន សមយេន ថេរា ភិក្ខូ នវេ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ក៏សម័យនោះភិក្ខុទាំងឡាយជាថេរៈ តែងទូន្មានប្រៀនប្រដៅ (ពួកភិក្ខុថ្មី ៗ។*

អប្បេកច្ចេ ថេរា ភិក្ខូ ទសបិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មានប្រៀនប្រដៅភិក្ខុ ១០ រូប ក៏មាន*

អប្បេកច្ចេ ថេរា ភិក្ខូ វីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មានប្រៀនប្រដៅភិក្ខុ ២០ រូបក៏មាន*

អប្បេកច្ចេ ថេរា ភិក្ខូ តិំសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មានប្រៀនប្រដៅ ភិក្ខុ ៣០ រូបក៏មាន*

អប្បេកច្ចេ ថេរា ភិក្ខូ ចត្តាឡីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មានប្រៀនប្រដៅភិក្ខុ ៤០ រូបក៏មាន ។*

តេ ច នវា ភិក្ខូ ថេរេហិ ភិក្ខូហិ ឱវទិយមានា អនុសាសិយមានា ឧឡារំ បុព្វេនាបរំ វិសេសំ ជានន្តិ *ចំណែកខាងភិក្ខុថ្មីអម្បាលនោះ កាលភិក្ខុទាំងឡាយជាថេរៈ កំពុងទូន្មានប្រៀនប្រដៅ ក៏ដឹងគុណវិសេសជាឧឡារិកជាងដើម ។*

តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ បវារណាយ បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ *សម័យនោះឯង ព្រះមានព្រះភាគ មាន*

*ភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងទីវាលស្រឡះ នាថ្ងៃបណ្ណរសឧបោសថនោះ គឺជាថ្ងៃបវារណាដ៏បរិបូណ៌ ក្នុងរាត្រីព្រះចន្ទពេញវង់ ។*

អថ ខោ ភគវា តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ *លំដាប់នោះ ព្រះមានព្រះភាគទ្រង់ទតភិក្ខុសង្ឃ ដែលអង្គុយស្ងៀម ហើយត្រាស់នឹងភិក្ខុទាំងឡាយថា*

អារទ្ធោស្មិ ភិក្ខវេ ឥមាយ បដិបទាយ; អារទ្ធចិត្តោស្មិ ភិក្ខវេ ឥមាយ បដិបទាយ *ម្នាលភិក្ខុទាំងឡាយ តថាគតត្រេកអរចំពោះបដិបទានេះ ម្នាលភិក្ខុទាំងឡាយ តថាគតមានចិត្តត្រេកអរចំពោះបដិបទានេះ ។*

តស្មាតិហ ភិក្ខវេ ភិយ្យោសោមត្តាយ វីរិយំ អារភថ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥធេវាហំ សាវត្ថិយំ កោមុទិំ ចាតុមាសិនិំ អាគមេស្សាមីតិ *ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរប្រារព្ធសេចក្តីព្យាយាមឲ្យលើសជាងប្រមាណចុះ ដើម្បីឲ្យដល់ធម៌ ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចធម៌ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ តថាគតនឹងរង់ចាំអ្នកទាំងឡាយក្នុងក្រុងសាវត្ថីនេះឯង អស់ទីបំផុតនៃខែបួន ដែលជាកាលមានផ្កាកុមុទរីក គឺ ខែកត្តិក ។*

អស្សោសុំ ខោ ជានបទា ភិក្ខូ ភគវា កិរ តត្ថេវ សាវត្ថិយំ កោមុទិំ ចាតុមាសិនិំ អាគមេស្សតីតិ *ភិក្ខុទាំងឡាយអ្នកនៅក្នុងជនបទបានឮដំណឹងថា ព្រះមានព្រះភាគនឹងរង់ចាំក្នុងក្រុងសាវត្ថីនោះឯង អស់ទីបំផុតបួនខែ ដែលជាកាលមានផ្កាកុមុទរីក ។*

តេ ជានបទា ភិក្ខូ សាវត្ថិំ ឱសរន្តិ ភគវន្តំ ទស្សនាយ *ទើបភិក្ខុអ្នកនៅក្នុងជនបទទាំងនោះ ប្រជុំគ្នាក្នុងក្រុងសាវត្ថី ដើម្បីជួបនឹងព្រះមានព្រះភាគ ។*

តេ ច ខោ ថេរា ភិក្ខូ ភិយ្យោសោមត្តាយ នវេ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ចំណែកភិក្ខុទាំងឡាយជាថេរៈនោះ ក៏ទូន្មានប្រៀនប្រដៅពួកភិក្ខុថ្មីឲ្យលើសជាងប្រមាណ ។*

អប្បេកច្ចេ ថេរា ភិក្ខូ ទសបិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ១០ រូបក៏មាន*

អប្បេកច្ចេ ថេរា ភិក្ខូ វីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មានប្រៀនប្រដៅភិក្ខុ ២០ រូបក៏មាន*

អប្បេកច្ចេ ថេរា ភិក្ខូ តឹសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ៣០ រូបក៏មាន*

អប្បេកច្ចេ ថេរា ភិក្ខូ ចត្តាឡីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ *ភិក្ខុជាថេរៈពួកខ្លះ ទូន្មានប្រៀនប្រដៅភិក្ខុ ៤០ រូបក៏មាន ។*

តេ ច នវា ភិក្ខូ ថេរេហិ ភិក្ខូហិ ឱវទិយមានា អនុសាសិយមានា ឧឡារំ បុព្វេនាបរំ វិសេសំ ជានន្តិ *ចំណែកភិក្ខុថ្មីអម្បាលនោះ កាលពួកភិក្ខុជាថេរៈ កំពុងទូន្មានប្រៀនប្រដៅ ក៏ដឹងគុណវិសេសជាឧឡារិកជាងដើមតទៅទៀត ។*

តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ កោមុទិយា ចាតុមាសិនិយា បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ *ក៏សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់នៅក្នុងទីវាល ក្នុងរាត្រីមានព្រះចន្ទពេញវង់ ជារាត្រីមានរដូវភ្លៀងគ្រប់គ្រាន់ហើយ ជាទីបំផុតនៃខែបួន ជាកាលមានផ្កាកុមុទរីក ជាថ្ងៃឧបោសថទី ១៥ គឺពេញបូណ៌មីខែកត្តិក ។*

អថ ខោ ភគវា តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ *លំដាប់នោះ ព្រះមានព្រះភាគទ្រង់ទតភិក្ខុសង្ឃ ដែលអង្គុយស្ងៀមហើយត្រាស់នឹងភិក្ខុទាំងឡាយថា*

អបលាបាយំ ភិក្ខវេ បរិសា *ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះស្ងាត់ហើយ*

និប្បលាបាយំ ភិក្ខវេ បរិសា សុទ្ធា សារេ បតិដ្ឋិតា *ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះស្ងាត់ចាកការចរចា ហើយស្ថិតនៅក្នុងធម៌ដែលជាខ្លឹមសារដ៏បរិសុទ្ធ ។*

តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ; តថារូបា អយំ ភិក្ខវេ បរិសា យថារូបា បរិសា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស *បរិស័ទមានសភាពយ៉ាងណាដែលគួរដល់ការបូជា គួរដល់អាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក។*

តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ; តថារូបា អយំ ភិក្ខវេ បរិសា យថារូបាយ បរិសាយ អប្បំ ទិន្នំ ពហុ ហោតិ ពហុ ទិន្នំ ពហុតរំ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះមានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះមានសភាពយ៉ាងនោះ ។ ទានតិចតួចដែលបុគ្គលឲ្យហើយទៅជាទានមានផលច្រើន ឬទានច្រើនដែលបុគ្គលឲ្យហើយ ក៏រឹងរឹតតែមានផលច្រើនក្នុងបរិស័ទមានសភាពយ៉ាងណា។*

តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ; តថារូបា អយំ ភិក្ខវេ បរិសា យថារូបា បរិសា ទុល្លភា ទស្សនាយ លោកស្ស *ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏មានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះក៏មានសភាពយ៉ាងនោះដែរ បរិស័ទមានសភាពយ៉ាងណា ដែលសត្វលោក បានឃើញដោយកម្រ ។*

តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ; តថារូបា អយំ ភិក្ខវេ បរិសា យថារូបំ បរិសំ អលំ យោជនគណនានិ ទស្សនាយ គន្តុំ បុដោសេនាបិ *ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះក៏មានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។ បរិស័ទមានសភាពយ៉ាងណា ដែលបុគ្គលគួរស្ពាយស្បៀង ដើរតាមរកមើលអស់ទីរាប់ដោយយោជន៍ គឺភិក្ខុសង្ឃ និងបរិស័ទដែលមានសភាពយ៉ាងនេះឯង ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសំយោជនា សម្មទញ្ញាវិមុត្តា ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ *ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ តែងមានពួកភិក្ខុជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌នៅរួចហើយ បានធ្វើកិច្ចដែលគួរស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ចំពោះខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់ហើយ មានចិត្តផុតវិសេសហើយ ព្រោះដឹងដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ *ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ តែងមានពួកភិក្ខុជាជាឱបបាតិកៈកំណើត*

ហើយបរិនិព្វានក្នុងលោកនោះ មិនវិលត្រឡប់ចាកលោកនោះមកវិញឡើយ គឺស្ថានសុទ្ធាវាស ព្រោះអស់សំយោជនៈជាចំណែកខាងក្រោម ៥ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មិំ ភិក្ខុសង្ឃេ តិណ្ណំ សំយោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ ឯវរូចាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មិំ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានភិក្ខុជាសកទាគាមី នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់សំយោជនៈ ៣ ព្រោះមានរាគៈ ទោសៈនិងមោហៈស្រាលស្តើង ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះតែងមាននៅក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មិំ ភិក្ខុសង្ឃេ តិណ្ណំ សំយោជនានំ បរិក្ខយា សោតាបន្នា អវិនិចាតធម្មា និយតា សម្ពោធិបរាយណា ឯវរូចាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មិំ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាសោតាបន្នៈ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិញ្ញាណប្រព្រឹត្តទៅខាងមុខ ព្រោះអស់សំយោជនៈ ៣ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះតែងមាននៅក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ចតុន្នំ សតិបដ្ឋានានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវសតិប្បដ្ឋានទាំង ៤ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ចតុន្នំ សម្មប្បធានានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវសម្មប្បធាន ៤ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ចតុន្នំ ឥទ្ធិបាទានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវឥទ្ធិបាទ ៤ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹំ ភិក្ខុសង្ឃេ បញ្ចន្នំ ឥន្ទ្រិយានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹំ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវឥន្ទ្រិយ ៥ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹំ ភិក្ខុសង្ឃេ បញ្ចន្នំ ពលានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹំ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវពលៈ ៥ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹំ ភិក្ខុសង្ឃេ សត្តន្នំ ពោជ្ឈង្គានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹំ ភិក្ខុសង្ឃេ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវពោជ្ឈង្គៈ ៧ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អរិយស្ស អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ *ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវមគ្គ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ មេត្តាភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ *ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះមានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវមេត្តា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ករុណាភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ *ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះមានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវករុណា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ មុទិតាភាវនានុយោគ-មនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ

*ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះមានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវមុទិតា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ឧបេក្ខាភាវនានុយោគ-មនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ

*ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះមានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវឧបេក្ខា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អសុភភាវនានុយោគ-មនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ

*ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះមានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវអសុភ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អនិច្ចសញ្ញាភាវនានុយោគ-មនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ *ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះមានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវអនិច្ចសញ្ញា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ។ ។*

សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អានាបានស្សតិ-ភាវនានុយោគមនុយុត្តា វិហរន្តិ ។ អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា *ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវអានាបានស្សតិ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលចម្រើនរឿយ ៗ ហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។*

អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា ចត្តារោ សតិប្បដ្ឋានេ បរិបូរេតិ *ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញ៉ាំងសតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូណ៌បាន ។*

ចត្តារោ សតិប្បដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ *សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញ៉ាំងពោជ្ឈង្គៈទាំង ៧ ឲ្យពេញបរិបូណ៌បាន ។*

សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ *ពោជ្ឈង្គៈទាំង ៧ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញ៉ាំងវិជ្ជានិងវិមុត្តិ ឲ្យពេញបរិបូណ៌បាន ។*

កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា *ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចម្រើនដូចម្តេច បានធ្វើឲ្យរឿយ ៗ ដូចម្តេច ទើបមានផល ច្រើន មានអានិសង្សច្រើន ?*

ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា *ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តម្កល់សតិមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។*

សោ សតោវ អស្សសតិ សតោវ បស្សសតិ *ភិក្ខុនោះ មានសតិដក ដង្ហើមចូល មានសតិដកដង្ហើមចេញ ។*

ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ *កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង, កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។*

រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ *កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី, កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី ។*

សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារគឺខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារគឺខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវ*

*សភាពមិនទៀង គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀង គ្រប់ខណៈដកដង្ហើមចេញ។*

វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចេញ។*

និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចេញ។*

បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចេញ ។*

ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា *ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើនយ៉ាងនេះ បានធ្វើឲ្យរឿយ ៗ យ៉ាងនេះ ទើបមានផលច្រើន មានអានិសង្សច្រើន ។*

កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា ចត្តារោ សតិបដ្ឋានេ បរិបូរេតិ *ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចម្រើន ដូចម្តេច បានធ្វើឲ្យរឿយ ៗ ដូចម្តេច ទើបញ៉ាំង សតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូណ៌បាន ?*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុកាលដកដង្ហើមចូល វែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលវែង, កាលដកដង្ហើមចេញ វែង ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញវែង ។*

រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ *កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចូលខ្លី, កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញ ដកដង្ហើមចេញខ្លី ។*

សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកងខ្យល់ទាំងពួង គឺខ្យល់ខាងដើម កណ្តាល និងខាងចុង ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារគឺខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងរម្ងាប់នូវកាយសង្ខារគឺខ្យល់ដ៏គ្រោតគ្រាត ល្អិត និងស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

កាយេ កាយានុបស្សី ភិក្ខវេ តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ។*

កាយេសុ កាយញ្ញតរាហំ ភិក្ខវេ ឯវំ វទាមិ យទិទំ អស្សាសបស្សាសា *ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ខ្យល់ចូល ខ្យល់ចេញ ជាកងរូបម្យ៉ាង ក្នុងកងរូបទាំងឡាយ ។*

តស្មាតិហ ភិក្ខវេ កាយេ កាយានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ *ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវកាយ ក្នុងកាយ មានព្យាយាមជា*

គ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ។

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវបីតិ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ ឲ្យរហូតនូវសុខ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុ*

*សិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្តសង្ខារស្ងប់ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

វេទនាសុ វេទនានុបស្សី ភិក្ខវេ តស្មិំ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗនូវវេទនា ក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ។*

វេទនាសុ វេទនាញ្ញតរាហំ ភិក្ខវេ ឯវំ វទាមិ យទិទំ អស្សាសបស្សាសានំ សាធុកំ មនសិការំ *ម្នាលភិក្ខុទាំងឡាយ តថាគតពោលថាការរលឹកដឹងខ្យល់ចូលនិងខ្យល់ចេញដ៏ល្អ ជាវេទនាម្យ៉ាង ក្នុងវេទនាទាំងឡាយ ។*

តស្មាតិហ ភិក្ខវេ វេទនាសុ វេទនានុបស្សី តស្មិំ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ *ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវវេទនា ក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ។*

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុសិក្សាថា អាត្មាអញនឹងកំណត់ដឹងច្បាស់ ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញ នឹងកំណត់ដឹងច្បាស់ឲ្យរហូតនូវចិត្ត ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យតាំងមាំស្មើ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ *ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងញ៉ាំងចិត្តឲ្យរួចផុតចាកនីវរណៈ ក្នុងខណៈកំពុងដកដង្ហើមចេញ ។*

ចិត្តេ ចិត្តានុបស្សី ភិក្ខវេ តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ។

នាហំ ភិក្ខវេ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតិំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលនូវអានាបានស្សតិរបស់ភិក្ខុដែលវង្វេងសតិ មិនប្រកបដោយបញ្ញាដឹងសព្វនោះទេ ។

តស្មាតិហ ភិក្ខវេ ចិត្តេ ចិត្តានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវចិត្ត ក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ។

យស្មឹ សមយេ ភិក្ខវេ ភិក្ខុ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិន

ទៀត គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវសភាពមិនទៀត គ្រប់ខណៈដកដង្ហើមចេញ។

វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវវិរាគៈ គ្រប់ខណៈដកដង្ហើមចេញ។

និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវនិរោធៈ គ្រប់ខណៈដកដង្ហើមចេញ។

បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចូល, ភិក្ខុសិក្សាថា អាត្មាអញនឹងជាប់តាមមើលនូវបដិនិស្សគ្គៈ គ្រប់ខណៈដកដង្ហើមចេញ ។

ធម្មេសុ ធម្មានុបស្សី ភិក្ខវេ តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកប

*ដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ។*

សោ យំ តំ អភិជ្ឈាទោមនស្សានំ បហានំ តំ បញ្ញាយ ទិស្វា សាធុកំ អជ្ឈុបេក្ខិតា ហោតិ *ភិក្ខុនោះ ជាអ្នកដឹងឃើញច្បាស់ការកម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ដោយបញ្ញាហើយ ជាអ្នកព្រងើយកន្តើយដោយល្អ។*

តស្មាតិហ ភិក្ខវេ ធម្មេសុ ធម្មានុបស្សី តស្មិំ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ *ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវធម៌ ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។*

ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា ចត្តារោ សតិប្បដ្ឋានេ បរិបូរេតិ *ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើនយ៉ាងនេះ បានធ្វើឲ្យរឿយៗ យ៉ាងនេះហើយ រមែងញុំាងសតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូណ៌បាន ។*

កថំ ភាវិតា ច ភិក្ខវេ ចត្តារោ សតិប្បដ្ឋានា កថំ ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ *ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំង ៤ ដែល*

បុគ្គលបានចម្រើនដូចម្ដេច បានធ្វើឲ្យរឿយៗ ដូចម្ដេច ទើបញុំាងពោជ្ឈង្គៈទាំង ៧ ឲ្យពេញបរិបូណ៌បាន ?

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ឧបដ្ឋិតាស្ស តស្មិំ សមយេ សតិ ហោតិ អសម្មុដ្ឋា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវកាយ ក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ក្នុងសម័យនោះ សតិដែលភិក្ខុនោះតម្កល់ខ្ជាប់ហើយ ក៏មិនបានវង្វេង។

យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា សតិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ សតិសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ សតិដែលភិក្ខុតម្កល់ខ្ជាប់ហើយមិនវង្វេងក្នុងសម័យណា ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ សម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនសតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ *ភិក្ខុនោះជាអ្នកមានសតិដូច្នោះ ក៏ជ្រើសរើស ត្រិះរិះដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា ។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ធម្មវិចយសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុមានសតិដូច្នោះ ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយបញ្ញាហើយ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។*

តស្ស តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ *ភិក្ខុនោះ កំពុងជ្រើសរើស កំពុងត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញាហើយ ក៏ប្រារព្ធនូវសេចក្តីព្យាយាមមិនឲ្យធូរថយឡើយ ។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ

វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ វីរិយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា បានប្រារព្ធសេចក្តីព្យាយាមមិនឲ្យធូរថយហើយ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះភិក្ខុឈ្មោះថាបានចម្រើនវីរិយសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ដោយការចម្រើនរបស់ភិក្ខុ។*

អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា *បីតិដែលប្រាសចាកអាមិសៈ ក៏កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាម។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ បីតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បីតិដែលប្រាសចាអាមិសៈ កើតឡើងដល់ភិក្ខុអ្នកប្រារព្ធព្យាយាមហើយ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនបីតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។*

បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ *កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ក៏ស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិ-សម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បើកាយរបស់ភិក្ខុមានចិត្តប្រកបដោយបីតិស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់ហើយ ក្នុងសម័យនោះ បស្សទ្ធិ-សម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ បស្សទ្ធិ-សម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។*

បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ *ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្ដីសុខ ក៏តាំងនៅខ្ជាប់ ។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ សមាធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្ដីតាំងនៅខ្ជាប់ហើយ ក្នុងសម័យនោះ សមាធិ-សម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា*

*បានចម្រើនសមាធិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។*

សោ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ *ភិក្ខុនោះ ញុំាងចិត្តដែលតាំងនៅខ្ជាប់ខ្ជួនហ្នឹង ឲ្យព្រងើយកន្តើយដោយស្រួល។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុញុំាងចិត្តដែលតាំងនៅខ្ជាប់ខ្ជួនហ្នឹង ឲ្យព្រងើយកន្តើយ ដោយស្រួលហើយ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ វេទនាសុ វេទនានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ឧបដ្ឋិតាស្ស តស្មិំ សមយេ សតិ ហោតិ អសម្មុដ្ឋា *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវវេទនា ក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស*

*ក្នុងលោកចេញ ក្នុងសម័យនោះ សតិដែលភិក្ខុនោះតម្កល់ខ្ជាប់ហើយ ក៏មិនបានវង្វេង។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា សតិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ សតិសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ សតិដែលភិក្ខុតម្កល់ខ្ជាប់ហើយមិនវង្វេងក្នុងសម័យណា ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ សម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនសតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។*

សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ *ភិក្ខុនោះជាអ្នកមានសតិដូច្នោះ ក៏ជ្រើសរើស ត្រិះរិះដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា ។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ធម្មវិចយសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុមានសតិដូច្នោះ ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយបញ្ញាហើយ*

ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

តស្ស តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ភិក្ខុនោះ កំពុងជ្រើសរើស កំពុងត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញាហើយ ក៏ប្រារព្ធនូវសេចក្តីព្យាយាមមិនឲ្យធូរថយឡើយ ។

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ វីរិយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា បានប្រារព្ធសេចក្តីព្យាយាមមិនឲ្យធូរថយហើយ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះភិក្ខុឈ្មោះថាបានចម្រើនវីរិយសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ដោយការចម្រើនរបស់ភិក្ខុ ។

អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា *បីតិដែលប្រាសចាកអាមិសៈ ក៏កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាម ។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា បីតិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ បីតិសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាចារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បីតិដែលប្រាសចាអាមិសៈ កើតឡើងដល់ភិក្ខុអ្នកប្រារព្ធព្យាយាម ហើយ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនបីតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។*

បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ *កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ក៏ស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់ ។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាចារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បើកាយរបស់ភិក្ខុមានចិត្តប្រកបដោយបីតិ ស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់ហើយ ក្នុងសម័យនោះ បស្សទ្ធិ-*

*សម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ បស្សទ្ធិ-សម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។*

បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ *ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្តីសុខ ក៏តាំងនៅខ្ជាប់ ។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ សមាធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្តីតាំងនៅខ្ជាប់ហើយ ក្នុងសម័យនោះ សមាធិ-សម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនសមាធិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។*

សោ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ *ភិក្ខុនោះញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយដោយស្រួល ។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ

ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយ ដោយស្រួលហើយ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើន ឧបេក្ខាសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយា ពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុ ចិត្តេ ចិត្តានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ឧបដ្ឋិតាស្ស តស្មឹំ សមយេ សតិ ហោតិ អសម្មុដ្ឋា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវចិត្ត ក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ចេញ ក្នុងសម័យនោះ សតិដែលភិក្ខុនោះតម្កល់ខ្ជាប់ហើយ ក៏មិនបាន វង្វេង។

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា សតិសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ សតិសម្ពោជ្ឈង្គំ តស្មឹំ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ សតិដែល ភិក្ខុតម្កល់ខ្ជាប់ហើយមិនវង្វេងក្នុងសម័យណា ក្នុងសម័យនោះ សតិ

សម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ សម័យនោះ ភិក្ខុឈ្មោះថាបាន ចម្រើនសតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយា ពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ ភិក្ខុនោះជាអ្នកមានសតិដូច្នោះ ក៏ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា ។

យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ធម្មវិចយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុមានសតិ ដូច្នោះ ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយបញ្ញាហើយ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុង សម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ ក្នុងសម័យ នោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការ ចម្រើនរបស់ភិក្ខុ ។

តស្ស តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វិរិយំ អសល្លីនំ ភិក្ខុនោះ កំពុងជ្រើសរើស កំពុងត្រិះរិះ ដល់

*នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញាហើយ ក៏ប្រារព្ធនូវសេចក្ដីព្យាយាមមិនឲ្យធូរថយឡើយ ។*

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុនោ តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ វីរិយសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ វីរិយសម្ពោជ្ឈង្គំ តស្មឹំ សមយេ ភិក្ខុ ភាវេតិ វីរិយសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ ភាវនាចារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា បានប្រារព្ធសេចក្ដីព្យាយាមមិនឲ្យធូរថយហើយ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះភិក្ខុឈ្មោះថាបានចម្រើនវីរិយសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ដោយការចម្រើនរបស់ភិក្ខុ។*

អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា *បីតិដែលប្រាសចាកអាមិសៈក៏កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាម។*

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា បីតិសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ បីតិសម្ពោជ្ឈង្គំ តស្មឹំ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ ភាវនាចារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បីតិដែលប្រាសចាអាមិសៈ កើតឡើងដល់ភិក្ខុអ្នកប្រារព្ធព្យាយាម*

*ហើយ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនបីតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។*

បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ *កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ក៏ស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បើកាយរបស់ភិក្ខុមានចិត្តប្រកបដោយបីតិស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់ហើយ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។*

បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ *ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្ដីសុខ ក៏តាំងនៅខ្ជាប់ ។*

យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ សមាធិសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ

សមាធិសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្តីតាំងនៅខ្ជាប់ហើយ ក្នុងសម័យនោះ សមាធិ-សម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនសមាធិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

សោ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ភិក្ខុនោះញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយដោយស្រួល ។

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរិំ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយ ដោយស្រួលហើយ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

យស្មិំ សមយេ ភិក្ខវេ ភិក្ខុ ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ឧបដ្ឋិតាស្ស

តស្មឹំ សមយេ សតិ ហោតិ អសម្មុដ្ឋា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុឈ្មោះថាពិចារណាឃើញរឿយៗ នូវធម៌ ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយបញ្ញាដឹងសព្វ មានសតិជាគ្រឿងកំណត់ កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ក្នុងសម័យនោះ សតិដែលភិក្ខុនោះតម្កល់ខ្ជាប់ហើយ ក៏មិនបាត់វង្វេង។

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា សតិសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ សតិសម្ពោជ្ឈង្គំ តស្មឹំ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ សតិដែលភិក្ខុតម្កល់ខ្ជាប់ហើយមិនវង្វេងក្នុងសម័យណា ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ សម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនសតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ ភិក្ខុនោះជាអ្នកមានសតិដូច្នោះ ក៏ជ្រើសរើស ត្រិះរិះដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា ។

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចយតិ បរិវីមំសំ អាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹំ

សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ធម្មវិចយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុមានសតិដូច្នោះ ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយបញ្ញាហើយ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។*

តស្ស តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ *ភិក្ខុនោះ កំពុងជ្រើសរើស កំពុងត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញាហើយ ក៏ប្រារព្ធនូវសេចក្តីព្យាយាមមិនឲ្យធូរថយឡើយ ។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចយតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ វីរិយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយបញ្ញា បានប្រារព្ធសេចក្តីព្យាយាមមិនឲ្យធូរថយហើយ ក្នុងសម័យ*

*នោះ វីរិយសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះភិក្ខុឈ្មោះថាបានចម្រើនវីរិយសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ដោយការចម្រើនរបស់ភិក្ខុ។*

អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា *បីតិដែលប្រាសចាកអាមិសៈក៏កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាម។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ។ បីតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បីតិដែលប្រាសចាកអាមិសៈ កើតឡើងដល់ភិក្ខុអ្នកប្រារព្ធព្យាយាមហើយ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនបីតិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។*

បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ *កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ក៏ស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់។*

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិ-

សម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បើកាយរបស់ភិក្ខុមានចិត្តប្រកបដោយបីតិស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់ហើយ ក្នុងសម័យនោះ បស្សទ្ធិ-សម្ពោជ្ឈង្គៈក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ បស្សទ្ធិ-សម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ។

បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្តីសុខ ក៏តាំងនៅខ្ជាប់ ។

យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ សមាធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្តីតាំងនៅខ្ជាប់ហើយ ក្នុងសម័យនោះ សមាធិ-សម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនសមាធិសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គៈ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។

សោ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ភិក្ខុនោះញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយដោយស្រួល ។

យស្មឹំ សមយេ ភិក្ខវេ ភិក្ខុ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ។ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មឹំ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹំ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ *ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុញ៉ាំងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយ ដោយស្រួលហើយ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើន ឧបេក្ខាសម្ពោជ្ឈង្គៈ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គៈក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចម្រើនរបស់ភិក្ខុ ។*

ឯវំ ភាវិតា ខោ ភិក្ខវេ ចត្តារោ សតិប្បដ្ឋានា ឯវំ ពហុលីកតា សត្ត សម្ពោជ្ឈង្គេ បរិបូរេន្តិ *ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចម្រើនយ៉ាងនេះ បានធ្វើឲ្យរឿយៗ ហើយ យ៉ាងនេះ រមែងញ៉ាំងពោជ្ឈង្គៈទាំង ៧ ឲ្យពេញបរិបូណ៌បាន ។*

កថំ ភាវិតា ច ភិក្ខវេ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ *ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គៈទាំង ៧ ដែលបុគ្គលចម្រើនហើយ ដូចម្ដេច បានធ្វើឲ្យរឿយៗ ហើយដូចម្ដេច ទើបញ៉ាំងវិជ្ជានិងវិមុត្តិ ឲ្យពេញបរិបូណ៌បាន ?*

៩៨ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ *ម្នាលភិក្ខុទាំងឡាយ*

*ភិក្ខុក្នុងសាសនានេះ ចម្រើនសតិសម្ពោជ្ឈង្គៈ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់នូវកិលេស ។*

ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ *ចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់នូវកិលេស ។*

វីរិយសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ *ចម្រើនវីរិយសម្ពោជ្ឈង្គៈ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់នូវកិលេស ។*

បីតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ *ចម្រើនបីតិសម្ពោជ្ឈង្គៈ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់នូវកិលេស ។*

បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ *ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់នូវកិលេស ។*

សមាធិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធ-និស្សិតំ វោស្សគ្គបរិណាមឹ *ចម្រើនសមាធិសម្ពោជ្ឈង្គៈ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់នូវកិលេស ។*

ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ *ចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ បង្អោនទៅដើម្បីលះបង់នូវកិលេស ។*

ឯវំ ភាវិតា ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ឯវំ ពហុលីកតា វិជ្ជាវិមុត្តិំ បរិបូរេន្តីតិ *ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គៈទាំង ៧ ដែលបុគ្គលចម្រើនហើយយ៉ាងនេះ បានធ្វើឲ្យរឿយៗ ហើយយ៉ាងនេះ ទើបញ៉ាំងវិជ្ជានិងវិមុត្តិឲ្យពេញបរិបូណ៌បាន ។*

ឥទមវោច ភគវា។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ *លុះព្រះមានព្រះភាគទ្រង់សម្ដែងនូវអានាបានស្សតិសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ មានសេចក្ដីពេញចិត្ត ត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ។*

អានាបានស្សតិសុត្តំ និដ្ឋិតំ

*អានាបានស្សតិសូត្រ ចប់ដោយប្រការៈដូច្នេះឯង ។*